## ជ័យលាភីលេខ១ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្ដេចតេជោ ហ៊ុន សែន»

### អបអរសាទរ ទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២


**យុវតី ជោ ស្រីណាង**

*ជាសិស្សថ្នាក់ទី ១២ នៃវិទ្យាល័យ ហ៊ុន សែន ពងទឹក ខេត្តស្វាយរៀង*


**ចំណងជើងកំណាព្យ៖ អំណានជួយលើកកម្ពស់គុណភាពជីវិតក្នុងសង្គមឌីជីថល**

(កំណាព្យបទ ពាក្យប្រាំពីរ)

១- កវីនិពន្ធជូនតាខ្មែរ លោកខំជួយថែរក្សាទុក
កំណាព្យកាព្យខ្មែរជាត្រីមុខ ប្រៀបបានជង្រុកដែលរឹងមាំ ។

២- សម្បត្តិវប្បធម៌ច្រើនអនេក អំណានបានចែកជាលំនាំ
ខិតខំសិក្សាដោយស៊ូទ្រាំ ស្វះស្វែងមុតមាំជាតិល្បាញល្បី ។

៣- អំណានត្រីមុខលើកកម្ពស់ ឱ្យជាតិខ្ពស់ខ្ពស់មានរស្មី
បំភ្លឺមនុស្សលោកទាំងប្រុសស្រី ប្រាជ្ញាស្មារតីច្នៃកើតមាន ។

៤- សិស្សរៀនសូត្រស្វ័យចំណេះ គ្រប់ផ្នែកឱ្យចេះគ្រប់ជំហាន
ប្រៀបបានមាគ៌ាដែលជាស្ពាន អប់រំទូន្មានស្វ័យសិក្សា ។

៥- យុគសម័យឌីជីថល តែងតែផ្ដល់ផលដល់ខេមរា
បានជួបជជែកស្វ័យសិក្សា គិតរាល់កិច្ចការប្រាជ្ញាវៃ ។

៦- អំណាចអំណានថ្កានគំនិត ផ្ដើមផ្ដល់ផលពិតល្អប្រពៃ
ឱ្យបំភ្លឺប្រាណបានជោគជ័យ ចេះគិតលកលៃច្នៃកិច្ចការ ។

៧- បច្ចេកវិទ្យាបង្កើតថ្មី មានលើផែនដីច្រើនអស្ចារ្យ
រៀនពីចម្ងាយគ្មានបញ្ហា បានជួបចរចាតាមបែបថ្មី ។

៨- ប្រព័ន្ធផ្សព្វផ្សាយជាតិជឿនលឿន បណ្ដាញជាល្បឿនលើវិថី
អនឡាញហ្គោហ្គលដោយសេរី លើកស្ទួយតម្លៃរបស់ជាតិ ។

៩- វិទ្យាសាស្ត្រលឿនល្បឿនយុទ្ធសាស្ត្រ សិក្សាយ៉ាងច្បាស់កុំបីឃ្លាត
ពង្រឹងបរិបទថ្មីថែមទៀត ស្របទៅតាមជាតិឌីជីថល ។

១០- ទិវាសួស្ដីថ្ងៃអំណាន លើកកម្ពស់បានទទួលផល
រក្សាសោភ័ណនឹងជួយផ្ដល់ ប្រាជ្ញាតម្កល់កុលបុត្រខ្មែរ ។

១១- អក្សរជាតិសាស្ត្រគឺជាគ្រឹះ បង្គោលជាឫសត្រូវខំថែ
មរតកអំណាននៃជាតិខ្មែរ គ្រប់រូបត្រូវតែថែឱ្យបាន ។

១២- ដូចនេះក្នុងនាមជនប្រុសស្រី ត្រូវប្រុងស្មារតីខំគ្រប់ប្រាណ
ក្រេបយកចំណេះពីអំណាន នោះជាតិថ្កើងថ្កានល្បីរន្ទឺ ៕

អំណាន READING

## ជ័យលាភីលេខ២ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្ដេចតេជោ ហ៊ុន សែន»

### អបអរសាទរ ទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២

**យុវតី ឈឺវ គឹមលេង**

*ជាសិស្សថ្នាក់ទី ១២ នៃវិទ្យាល័យហ៊ុន សែន ចំការដូង ខេត្តកែប*

**ចំណងជើងកំណាព្យ៖ អំណានជួយលើកកម្ពស់គុណភាពជីវិតក្នុងសង្គមឌីជីថល**

(កំណាព្យបទ ពាក្យប្រាំពីរ)

១- ហ្គូលហ្គូលយូធូបឯកសារល្អ អនឡាញបន្តផ្ដល់ឥតប្រែ
ស្វែងរកខ្លឹមសារជាហូរហែ បណ្ណាល័យក្បែរថៃថ្លើងថ្កាន ។

២- អំណានប្រៀបបាននឹងអំណាច ឫទ្ធាអង់អាចជ្រែកសព្វឋាន
ជួយឃិតជួយយោងជ្រោងឱ្យបាន តម្រង់ការអានសាន្តសុខា ។

៣- អំណានលើកស្ទួយជួយជីវិត បងប្អូនញាតិមិត្តគិតឧស្សាហ៍
បណ្ដុះការអានយ៉ាងខ្លាំងក្លា ពង្រឹងវាសនាឱ្យខ្ពង់ខ្ពស់ ។

៤- ក្នុងយុគសម័យឌីជីថល អំណានបានផ្ដល់ផលច្រើនហួស
គុណភាពជីវិតពិតជំនួស កើតកើនសក្ដិយសឈ្មោះរណ្ដំ ។

៥- ចំណេះពេញពោរសម្បូរបែប កៀកកិតជិតអែបគួរខិតខំ
ប្រឹងប្រែងស្រាវជ្រាវកុំសំងំ យកមកលាយឡំផ្សំឱ្យចេះ ។

៦- អំណានប្រៀបបាននឹងអំណោយ ចំណែកចែកឱ្យដោយចំណេះ
បង្កើតគំនិតគិតចាំចេះ មិនពុករបេះមិនច្រែះឡើយ ។

៧- អំណានប្រៀបបាននឹងរស្មី ជួយជនប្រុសស្រីឱ្យបានស្បើយ
ចាកភពងងឹតពិតល្ហែល្ហើយ ជីវិតដល់ត្រើយកើយសុខា ។

៨- អានហើយសប្បាយស្រាយចម្ងល់ ស្រាយភាពខ្វាយខ្វល់ផ្ដល់បញ្ញា
ពិភពលោកថ្មីល្បីអស្ចារ្យ ជាតិជាខេមរាស្គាល់កិត្តិយស ។

៩- អានជាអំណោយដល់ខួរក្បាល វិសេសវិសាលថ្កាលកេរ្ដិ៍ឈ្មោះ
ស្រោចស្រង់ជីវិតពិតខ្ពង់ខ្ពស់ គ្មានអ្វីជំនួសឈ្មោះឧត្ដម ។

១០- អបអរទិវាជាតិអំណាន បំផុសការអានយ៉ាងស័ក្ដិសម
ស្រាវជ្រាវរាវរកយកផ្សែផ្សំ អស់ក្ដីបារម្ភខំឥតព្រួយ ។

១១- ដូច្នេះកុលបុត្រកុលធីតា ស្វះស្វែងសិក្សាជាធ្លុងមួយ
វិស័យអំណានបានលើកស្ទួយ ជាងបានជំនួយជួយជាតិខ្មែរ ៕

## ជ័យលាភីលេខ៣ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន»

### អបអរសាទរ ទិវាជាតិអំណានលើកទី៧ ១១ មីនា ២០២២

**យុវជន ឡោ សុជា**

*ជាសិស្សថ្នាក់ទី ១២ នៃវិទ្យាល័យជាស៊ីមឈូកវ៉ា រាជធានីភ្នំពេញ*

**ចំណងជើងកំណាព្យ៖ ស្មាតឌីជីថល**

(កំណាព្យបទ ពាក្យប្រាំពីរ)

១- ដែនដីកម្ពុជាប្រពៃ
ប្រជាប្រុសស្រីមានវិជ្ជា
ចំណេះដ៏ច្រើនមហិមា
ជួយអ្នកគ្រប់គ្នាឱ្យសិក្សា ។

២- ទោះជាសព្វថ្ងៃមានឧបសគ្គ
រាប់រយដំណាក់មកប្រហារ
មិនអាចបំបាត់រាជរដ្ឋា
និងបើកសាលាលែងភិតភ័យ ។

៣- នេះជាសម័យតេជោស្មាត
បានអនុញ្ញាតវត្តមានថ្មី
បច្ចេកវិទ្យាដ៏ល្បាញល្បី
នាំជនប្រុសស្រីរស់សុខសាន្ត ។

៤- ការរៀន និងរស់តាមបែបបទ
ឌីជីថលកត់សុខគ្រប់ប្រាណ
គ្រប់មុខរបរប្រសើរបាន
ឧបទ្រពប៉ុន្មានរួចចាកទុក្ខ ។

៥- ដំណឹងព័ត៌មានផ្សាយរហ័ស
ទាក់ទងបានច្បាស់មិនស្មាញស្មុគ
តាមអ៊ីនធឺណេតគ្រប់ភូមិស្រុក
ប្រឹងប្រើសម្រុកមិនខ្វល់ខ្វាយ ។

៦- ប្រភពព័ត៌មានវិទ្យាពិត
ឱ្យអស់ញាតិមិត្តរួមសប្បាយ
ទោះនៅទីជិតឬទីឆ្ងាយ
ប្រព័ន្ធផ្សព្វផ្សាយមិនកំណត់ ។

៧- ប្រទេសបច្ចេកវិទ្យាដល់
អស់ភាពកង្វល់ភាពនឿយហត់
ធូរស្បើយកម្លាំងពិតប្រាកដ
យើងលែងកម្សត់ព្រោះជំនួយ ។

៨- ប្រទេសនាមមហាអំណាច
លូតលាស់មិនខ្លាចមិនភ័យព្រួយ
ព័ត៌មានវិទ្យាជួយលើកស្ទួយ
ប្រទេសមួយៗរីកចម្រើន ។

៩- អ៊ីនធឺណេតជាបរិក្ខារ
ឱ្យមនុស្សារចេះបង្កើន
ភាពស្និទ្ធភាពស្នាលបានជាច្រើន
អាយុយឺនកើនពេញមុខមាត់ ។

១០- ជម្រាបរៀបរាប់តែប៉ុណ្ណឹង
សំឡេងកណ្តឹងបានសន្មត
ថេរវេលាបានកំណត់
សូមលាប្រាកដតែត្រឹមហ្នឹង ៕